ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២៩២/០០៩/២០១៤

ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤

**សេចក្តីសម្រេច**

លេខ : ១៥១/០០៥/២០១៤ កបធ.ច

ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ១៩២/០៨១៤/ពស/ន.រ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ របស់ឯកឧត្តម **សាយ ឈុំ** ប្រធានស្តីទីព្រឹទ្ធសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ នៃព្រះរាជាណាចក្រកម្ពុជា ដែលព្រឹទ្ធសភាបានអនុម័តនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ ព្រឹទ្ធសភានីតិកាលទី៣ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ វេលាម៉ោង ១៤:០០។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិនៃមាត្រា ១១៤ ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ និងប្រការ ៨២ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដែលប្រកាសឱ្យប្រើតាមសេចក្តីសម្រេចលេខ ០១៧/០៨១២/ពស/សរ.ព ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១២ ក្នុងការពិនិត្យនិងអនុម័តសេចក្តីស្នើ

វិសោធនកម្មប្រការ ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣នៃព្រះរាជាណាចក្រកម្ពុជា

- យល់ឃើញថា សំណើរបស់ឯកឧត្តម **សាយ ឈុំ** ប្រធានស្តីទីព្រឹទ្ធសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣នេះមកពិនិត្យបាន

- យល់ឃើញថា ទម្រង់នៃការតាក់តែងនិងការអនុម័តវិសោធនកម្មប្រការ ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ នៃព្រះរាជាណាចក្រកម្ពុជា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ខ្លឹមសារនៃប្រការ ១៥ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ នៃព្រះរាជាណាចក្រកម្ពុជា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

## សម្រេច

**មាត្រា ១.** វិសោធនកម្មប្រការ ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ នៃព្រះរាជាណាចក្រកម្ពុជា ដែលព្រឹទ្ធសភាបានអនុម័តនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ ព្រឹទ្ធសភា នីតិកាលទី៣ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៤ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល